១.អបអរសាទរពិធីទទួលវិញ្ញាបន

ឯកឧត្តម យ៉ោក សុទ្ធី
នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស

សូមស្វាគមន៍ ការមកកាន់ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI) ដែលជាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស ឈានមុខមួយក្នុងចំណោមគ្រឹះស្ថានអប់រំបណ្តុះបណ្តាល នៃព្រះរាជាណាចក្រកម្ពុជា។

NTTI បានបង្កើតឡើងជាផ្លូវការដោយអនុក្រឹត្យលេខ ១០៩ ចុះថ្ងៃទី ២៩ នៃ តុលា ឆ្នាំ ២០០១ ស្ថិតនៅក្រោមការគ្រប់គ្រង ក្រសួងអប់រំ យុវជន និងកីឡា។ បច្ចុប្បន្ន NTTI បានផ្លាស់ប្តូរឲ្យមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ យោងទៅលើបទពិសោធន៍ការងារ ក្នុងរយៈពេលដ៏យូរដោយចាប់តាំងពីឆ្នាំ ១៩៩៩ មក NTTI បានកសាងកេរ្តិ៍ឈ្មោះនិងគុណភាពអប់រំឲ្យទទួលបាននូវភាពល្បីល្បាញទាំងក្នុងនិងក្រៅប្រទេស។ អស់រយៈជាងមួយទស្សវត្ស NTTI បានអភិវឌ្ឍន៍ធនធានមនុស្សលើផ្នែក គ្រូបច្ចេកទេសវិជ្ជាជីវៈ ផ្នែកវិស្វកម្ម និងផ្នែកបច្ចេកវិទ្យា ដែលធនធានទាំងអស់នោះបាននិងកំពុងបម្រើសេចក្តីត្រូវការនៅពាសពេញផ្ទៃប្រទេស។ សមិទ្ធិផលសម្រេចទាំងនេះ បង្ហាញអោយឃើញថា NTTI បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិលើការបណ្តុះបណ្តាល ផ្នែកបច្ចេកវិទ្យាពីជំនាន់មួយទៅជំនាន់មួយ ដោយប្រើប្រាស់កម្មវិធីសិក្សាទំនើប តម្រូវតាមទីផ្សារការងារ ដែលត្រូវបានរៀបចំឡើងដោយមន្ត្រី និងសាស្ត្រាចារ្យ ដែលមានបទពិសោធន៍ការងារច្រើនឆ្នាំ។ មុខវិជ្ជាសិក្សា ត្រូវបានរៀបចំយ៉ាងយកចិត្តទុកដាក់ ដើម្បីឲ្យស្របតាមរបៀបវារៈ នៃការកសាង និងកំណែទម្រង់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស ស្ថិតនៅក្នុងមុំមួយ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ទាំងអស់នេះ ត្រូវពឹងផ្អែកលើការខិតខំប្រឹងប្រែង ពីក្រុមបច្ចេកទេសទាំងអស់ នៃវិទ្យាស្ថានដើម្បីបន្តធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ។ វិទ្យាស្ថាន បាននិងកំពុងផ្តល់នូវការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ កម្រិតជាន់ខ្ពស់បច្ចេកទេស បរិញ្ញាបត្រគ្រូបច្ចេកវិទ្យា និង កម្រិតម៉ាស្ទ័របច្ចេកវិទ្យា ផ្នែកវិស្វកម្មសំណង់ស៊ីវិល អគ្គិសនី និងអេឡិចត្រូនិច ព័ត៌មានវិទ្យា និងស្ថាបត្យកម្ម។ លើសពីនេះទៅទៀត NTTI ក៏ជាមជ្ឈមណ្ឌលបណ្តុះបណ្តាល គ្រូបច្ចេកទេសវិជ្ជាជីវៈ ដែលក្នុងមួយឆ្នាំៗ ធ្វើការបណ្តុះបណ្តាលគ្រូបច្ចេកទេសវិជ្ជាជីវៈ តម្រូវទៅតាមការអភិវឌ្ឍន៍ និងការរីកចំរើនរបស់ប្រទេសជាតិ។ នាពេលបច្ចុប្បន្ន ក្នុងការរៀន និងបង្រៀនទាំងអស់ត្រូវបានលើកទឹកចិត្ត ឱ្យខិតខំសិក្សាជាមួយ នឹងបរិស្ថានល្អប្រសើរ ដែលត្រូវបានរៀបចំឡើង សម្រាប់អាជីពក្នុងការរៀន និងបង្រៀន ដោយមានទីតាំង និងបរិវេណធំទូលាយ ស្រស់ស្អាត ដែលធ្វើឱ្យនិស្សិត មន្ត្រី បុគ្គលិក ព្រមទាំងសាស្ត្រាចារ្យទាំងអស់ តែងតែមានអារម្មណ៍ជឿជាក់ និងសុទិដ្ឋិនិយមជានិច្ច។

គោលបំណងរបស់វិទ្យាស្ថាន គឺផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានគុណភាពខ្ពស់ សុជីវធម៌ និងសីលធម៌វិជ្ជាជីវៈ ដល់សិស្ស និស្សិត ដើម្បីតម្រង់ទិស ពួកគេឱ្យចូលក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ អាទិភាពដំបូងរបស់វិទ្យាស្ថាន សម្រាប់ការអភិវឌ្ឍន៍ គឺការផ្តល់នូវការបំពាក់សម្ភារៈទំនើបកម្មក្នុងមន្ទីរពិសោធន៍ និងការទទួលបាននូវសៀវភៅ សម្ភារៈសិក្សាទំនើបៗព្រមទាំងការបំពាក់នូវប្រព័ន្ធអ៊ិនធឺណេត ដើម្បីងាយស្រួលដល់ការស្រាវជ្រាវ របស់មន្ត្រី សាស្ត្រាចារ្យ បុគ្គលិក និងសិស្ស និស្សិត។

តាងនាមឱ្យថ្នាក់ដឹកនាំ មន្ត្រី សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ខ្ញុំបាទស្វាគមន៍ នូវរាល់ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនង ក្នុងការកសាងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសគ្រប់កម្រិតជា គ្រឹះសម្រាប់អភិវឌ្ឍន៍ធនធានមនុស្សរបស់កម្ពុជាអោយបានរឹងមាំ។

អានបន្ត៖ មតិស្វាគមន៍នាយកវិទ្យាស្ថាន

នាយកវិទ្យាស្ថាន
ឈ្មោះ: ឯកឧត្តម យ៉ោក សុទ្ធី
ទូរស័ព្ទ: ០១២ ៦៦៧ ៧៥៣
អ៊ីម៉ែល: yok.sothy@ntti.edu.kh

នាយករងរដ្ឋបាល និងហិរញ្ញវត្ថុ
ឈ្មោះ: ឯកឧត្តម ឆ ខេមរិន្ទ
ទូរស័ព្ទ: ០១២ ៣០០ ០៦០
អ៊ីម៉ែល: khemrin@ntti.edu.kh

នាយករងអប់រំ
ឈ្មោះ: ឯកឧត្តម ម៉ុម សូម៉ាច
ទូរស័ព្ទ: ០១២ ៧៧២ ៨២៨
អ៊ីម៉ែល: mom_somach@yahoo.com

នាយិការងសិក្សា
ឈ្មោះ: លោកជំទាវ ហែម សុខច័ន្ទ
ទូរស័ព្ទ: ០១២ ៨៥៩ ៩០១
អ៊ីម៉ែល: sokchan@ntti.edu.kh

ប្រធានផ្នែក
ឈ្មោះ: លោក មាស សារិទ្ធ
ទូរស័ព្ទ: ០១២ ៥៦៧ ៦៥១
អ៊ីម៉ែល: meas_sarith@ntti.edu.kh

ប្រធានដេប៉ាតឺម៉ង់
ឈ្មោះ: លោក ទុន សោភ័ន
ទូរស័ព្ទ: ០១៧ ៥៦៦ ៩៧៧
អ៊ីម៉ែល: sorphorntun@ntti.edu.kh

ប្រធានដេប៉ាតឺម៉ង់
ឈ្មោះ: លោក ឯក ផាន់ណារ៉ាន់
ទូរស័ព្ទ: ០១២ ៩៥៧ ៦៨៩
អ៊ីម៉ែល: rann@ntti.edu.kh

ប្រធានផ្នែក
ឈ្មោះ: លោក សុខ សាកូរា
ទូរស័ព្ទ: ០៧៨ ៩២៧ ៨១០
អ៊ីម៉ែល: sakora@ntti.edu.kh

ប្រធានផ្នែក
ឈ្មោះ: លោក ឌី ឡុង
ទូរស័ព្ទ: ០១១ ៦៦៦ ២២៦
អ៊ីម៉ែល: dylong@ntti.edu.kh

ប្រធានដេប៉ាតឺម៉ង់
ឈ្មោះ: លោក ប្រាក់ សំអុល
ទូរស័ព្ទ: ០៩៧៧ ៦១០ ៨៣១
អ៊ីម៉ែល: p.samol@ntti.edu.kh

ប្រធានដេប៉ាតឺម៉ង់
ឈ្មោះ: លោក ម៉ន អ៊ីន
ទូរស័ព្ទ: ០១២ ៩២០ ៥៦៥
អ៊ីម៉ែល: inn@ntti.edu.kh

ប្រធានដេប៉ាតឺម៉ង់
ឈ្មោះ: លោក សេក ច័ន្ទជាលី
ទូរស័ព្ទ: ០១២ ៦៧៦ ៧៩២
អ៊ីម៉ែល: chealy@ntti.edu.kh

ប្រធានផ្នែក
ឈ្មោះ: លោក សោម វ៉ាន់ដន
ទូរស័ព្ទ: ០១២ ៣០៩ ៥៥៦
អ៊ីម៉ែល: somvandorn@ntti.edu.kh

PROCAST CO.LTD

FIND US ON FACEBOOK



LANGUAGE

KHMER ENGLISH

NEWS AND EVENTS

សេចក្តីជូនដំណឹងសម្រាប់និស្សិតព័ត៌មានវិទ្យា

សេចក្តីជូនដំណឹងសម្រាប់និស្សិតព័ត៌មានវិទ្យា

...Read more
24 Jan 2018

ឯកឧត្តមបណ្ឌិត យ៉ោកសុទ្ធី នាយកNTTI បានចូលរួមក្នុងកម្មវិធីសំណេះសំណាលជាមួយមន្ត្រីរាជការ

ឯកឧត្តមបណ្ឌិត យ៉ោកសុទ្ធី នាយកNTTI បានចូលរួមក្នុងកម្មវិធីសំណេះសំណាលជ...Read more
24 Jan 2018

APPLICATION FORM

Students who wish to apply for admission to NTTI must fill out the application form. Please click download for
[207] Student Application Form
[207] Pedagogy Student Form

Media

សម្តេចតេជោ ហ៊ុន សែន អញ្ជើញប្រគល់សញ្ញាបត្រដល់ គរុនិស្សិត និងនិស្សិត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ថ្ងៃទី០៧ នៃខែវិច្ឆិកា ឆ្នាំ២០១៦

ភ្នំពេញ៖ សម្តេចតេជោ ហ៊ុន សែន នៅព្រឹកថ្ងៃទី៧ នៃខែវិច្ឆិកាបានអញ្ជើញជ...Read more
04 Jan 2017

COMMUNITY ACTIVITIES

វគ្គបណ្តុះបណ្តាលច្បាប់ចរាចរណ៍

បុគ្គលិកនិងនិស្សិតនៃវិទ្យាស្ថានមានត្រូវបានជម្រុញឱ្យចូលរួមក្នុ...Read more
06 Jun 2016

HACKED

HACKED BY BDJ-007

...Read more
06 Jun 2016

SCHOLARSHIP

Offer 100% Scholarship to Senior and Junior Technical Students in Pedagogy.
Read more

HOW TO APPLY

1. Master Degree
2. Bachelor Degree
3. Diploma Degree (Associate)

Read more

WHO IS ONLINE

635

Today	1060
This Week	15764
This Month	67626
One Year	628436
Forecast Today	1840

Copyright © 2016 (NTTI). All rights reserved.

Address: Russian Blvd, Sangkat Teukthla Khan Sensok, Phnom Penh, Cambodia